ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

នាយកដ្ឋានសវនកម្មផ្ទៃក្នុង

# របាយការណ៍សវនកម្មផ្ទៃក្នុង

# នៅមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តបន្ទាយមានជ័យ

**លេខ:..........០៦៩..........របក/សផក**

ខែ ពិសាខ ឆ្នាំរោង ឆស័ក ព.ស. ២៥៦៧

**ខែឧសភា ឆ្នាំ២០២៤**

## ព័ត៌មានស្តីពីឯកសារ

- ឯកសារសង្ខេប:

| | |
|---|---|
| នាយកដ្ឋានសវនកម្មផ្ទៃក្នុង | ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ |
| ចំណងជើង | របាយការណ៍សវនកម្ម |
| ប្រធានប្រតិភូ | លោក **យួន សុជាតិ** |
| អ្នកត្រួតពិនិត្យ | ប្រធាននាយកដ្ឋានសវនកម្មផ្ទៃក្នុង |
| សវនដ្ឋាន | **មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តបន្ទាយមានជ័យ** |
| ទីកន្លែងឯកសាររឹង | នាយកដ្ឋានសវនកម្មផ្ទៃក្នុង ការិយាល័យសវនកម្មទី៣ |
| ទីកន្លែងឯកសារទន់ | ការិយាល័យសវនកម្មទី៣ |

- ការបែងចែកឯកសារ:

| ឈ្មោះ | មុខតំណែង/តួនាទី | កន្លែងទទួល |
|---|---|---|
| ឯកឧត្តម **សាយ សំអាល់** | ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួង រៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | ខុទ្ទកាល័យក្រសួង( ដ. ន. ស) |
| លោកជំទាវ **សោម គីមសួគ៌** | អគ្គសវនករ នៃអាជ្ញាធរសវនកម្មជាតិ | អាជ្ញាធរសវនកម្មជាតិ |
| លោក **មាស ដារ៉ា** | ប្រធានមន្ទីរស្តីទីនៃមន្ទីររៀបចំដែនដី នគរូបនីកម្ម សំណង់ និងសុរិយោដីខេត្តបន្ទាយមានជ័យ | មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តបន្ទាយមានជ័យ |

# មាតិកា


ទំព័រ

**ផ្នែក ក: ខ្លឹមសារសង្ខេប**........ ៤

១. សាវតារ ........ ៤

២. ហានិភ័យគន្លឹះ ........ ៤

៣. វិសាលភាពសវនកម្ម ........ ៤

៤. គោលបំណងសវនកម្ម និងការត្រួតពិនិត្យ ........ ៥

៥. អភិក្រមសវនកម្ម ........ ៥

៦. សង្ខេបលទ្ធផលគន្លឹះ ........ ៦

៧. សេចក្តីសន្និដ្ឋាន ........ ៦

៨. វិធានការកែលម្អ ........ ៧

៩. អំណរគុណ ........ ៧

**ផ្នែក ខ: លទ្ធផលសវនកម្មលម្អិត**........ ៧

១. ធនធានសវនកម្ម និងខណៈគោលសំខាន់ៗ ........ ៧

២. ទិដ្ឋភាពរួមសវនកម្មផ្ទៃក្នុង ........ ៨

៣. ការពិនិត្យការគ្រប់គ្រងផ្ទៃក្នុង ........ ៨

៤. ព័ត៌មានអំពីសវនដ្ឋាន ........ ៨

៥. លទ្ធផលសវនកម្ម ........ ៩

៥.១. ផ្នែកប្រតិបត្តិការ ........ ៩

ក. ការទូទាត់ប្រាក់បេសកកម្ម ........ ៩

៥.២. ផ្នែកអនុលោមភាព ........ ៩

ក. ការអនុវត្តការងារសំណង់ ........ ៩

ខ. ការអនុវត្តការងារសុរិយោដី និងភូមិសាស្ត្រ ........ ១០

គ. ការប្រើប្រាស់ប្រព័ន្ធព័ត៌មានភូមិសាស្ត្រ........ ១១

ឃ. ការងារសុរិយោដី និងភូមិសាស្ត្រ និងកម្មវិធីអនុវិស័យរដ្ឋបាលដីធ្លី ........ ១២

៦. សេចក្តីសន្និដ្ឋានរួម ........ ១២

៧. ផែនការសកម្មភាពកែលម្អ........ ១៣

**ឧបសម្ព័ន្ធ÷**

-ឧបសម្ព័ន្ធទី ២ ផែនការសកម្មភាពកែលម្អ

-ឧបសម្ព័ន្ធទី ៣ តារាងចំណាយថវិការដ្ឋ និងតារាងប្រើប្រាស់ប្រេងឥន្ធនៈ

# ផ្នែក ក: ខ្លឹមសារសង្ខេប

## ១. សាវតារ

ការធ្វើសវនកម្មនៅមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តបន្ទាយមានជ័យ សម្រាប់ការិយបរិច្ឆេទ២០២៣ ជាផ្នែកមួយនៃផែនការប្រចាំឆ្នាំ របស់នាយកដ្ឋានសវនកម្មផ្ទៃក្នុងលេខ ១២០ ដនស/នា.សផក ចុះថ្ងៃទី២៣ ខែមករា ឆ្នាំ២០២៤ ដែលទទួលបានការយល់ព្រមពី **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងបានចុះអនុវត្តតាមលិខិតបញ្ជាបេសកកម្មលេខ ៩៤៨,៩៥០ ដនស ចុះថ្ងៃទី០៣ ខែមេសា ឆ្នាំ២០២៤។ របាយការណ៍នេះមានព័ត៌មានលម្អិតអំពីលទ្ធផលការងារសវនកម្ម និងការផ្តល់អនុសាសន៍ក៏ដូចជាវិធានការរបស់ថ្នាក់គ្រប់គ្រងដែលបានឯកភាពគ្នា។

**២. ហានិភ័យគន្លឹះ** ជាទូទៅហានិភ័យអាចរាប់បញ្ចូលនូវ:

**ហានិភ័យប្រតិបត្តិការ:** ជាហានិភ័យលើការបាត់បង់ដែលជាលទ្ធផលបរាជ័យនៃដំណើរការមនុស្ស និងប្រព័ន្ធ ឬពីហេតុការណ៍ពីខាងក្រៅ។

**ហានិភ័យហិរញ្ញវត្ថុ:** ជាលទ្ធភាពដែលព័ត៌មានផ្នែកហិរញ្ញវត្ថុត្រូវបានរៀបចំឡើងមិនត្រឹមត្រូវ ធ្វើឱ្យការសម្រេចចិត្តរបស់ថ្នាក់ដឹកនាំពុំសមស្រប។

**ហានិភ័យអនុលោមភាព:** ជាលទ្ធភាពដែលសកម្មភាពមិនអនុលោមតាមច្បាប់ និងបទប្បញ្ញត្តិ។

ដោយឡែក ការងារសវនកម្មនៅមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តបន្ទាយមានជ័យ មន្ត្រីសវនករកំណត់បាននូវហានិភ័យមួយចំនួន ក្នុងនោះហានិភ័យគន្លឹះមាន:

- ការប៉ះពាល់ដល់ការទូទាត់ប្រាក់បេសកកម្ម
- ការប៉ះពាល់ដល់ការអនុវត្តការងារសំណង់
- ការប៉ះពាល់ដល់ការអនុវត្តការងារសុរិយោដី និងភូមិសាស្ត្រ
- ការប៉ះពាល់ដល់ការការប្រើប្រាស់ប្រព័ន្ធព័ត៌មានភូមិសាស្ត្រ
- ការប៉ះពាល់ដល់ការងារសុរិយោដី និងភូមិសាស្ត្រ និងកម្មវិធីអនុវិស័យរដ្ឋបាលដីធ្លី

## ៣. វិសាលភាពសវនកម្ម

សវនកម្មនេះគ្របដណ្តប់លើសកម្មភាពគ្រប់គ្រង និងប្រតិបត្តិការទាំងឡាយដែលបានដំណើរការដោយមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តបន្ទាយមានជ័យ សម្រាប់ការិយបរិច្ឆេទ ២០២៣។ ការប្រមូលព័ត៌មានសវនកម្ម និងការធ្វើតេស្តសវនកម្មត្រូវបានប្រព្រឹត្តទៅនៅការិយាល័យរដ្ឋបាលនៃមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តបន្ទាយមានជ័យ ការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលក្រុងប៉ោយប៉ែត និងការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលក្រុងសិរីសោភ័ណ។

## ៤. គោលបំណងសវនកម្ម និងការត្រួតពិនិត្យ

គោលបំណងសវនកម្មរួមគឺ វាយតម្លៃ និងធ្វើឱ្យប្រសើរឡើងនូវប្រសិទ្ធភាពនៃដំណើរការគ្រប់គ្រងហានិភ័យ ដំណើរការត្រួតពិនិត្យ និងដំណើរការអភិបាលកិច្ចក្នុងទីសវនកម្មដែលស្ថិតនៅក្នុងវិសាលភាពសវនកម្ម។

ជាទូទៅ ការងារសវនកម្មបានផ្តោតសំខាន់ទៅលើប្រព័ន្ធគ្រប់គ្រងផ្ទៃក្នុង ដែលអាចផ្តល់នូវការធានាសមហេតុផលមួយ សំដៅសម្រេចបាននូវគោលបំណងដូចខាងក្រោម៖

- **គោលបំណងប្រតិបត្តិការ:** ការសម្រេចបានប្រកបដោយប្រសិទ្ធភាព នៃគោលបំណងធុរកិច្ច។
- **គោលបំណងព័ត៌មាន:** ភាពជឿទុកចិត្ត និងភាពពេញលេញនៃព័ត៌មានផ្នែកហិរញ្ញវត្ថុ ដែលប្រើប្រាស់ដោយថ្នាក់ដឹកនាំ។
- **គោលបំណងអនុលោមភាព:** អនុលោមជាមួយច្បាប់ បទប្បញ្ញត្តិ គោលការណ៍ នីតិវិធីជាធរមាន។

ដោយឡែក នៅក្នុងសវនកម្មនេះ សវនករបានកំណត់នូវគោលបំណងសំខាន់ៗមួយចំនួនដើម្បីគ្រប់គ្រងហានិភ័យដូចជា:

- ប្រសិទ្ធភាពនៃការទូទាត់ប្រាក់បេសកកម្ម
- ប្រសិទ្ធភាពនៃការអនុវត្តការងារសំណង់
- ប្រសិទ្ធភាពនៃការអនុវត្តការងារសុរិយោដី និងភូមិសាស្ត្រ
- ប្រសិទ្ធភាពនៃការប្រើប្រាស់ប្រព័ន្ធព័ត៌មានភូមិសាស្ត្រ
- ប្រសិទ្ធភាពនៃការងារសុរិយោដី និងភូមិសាស្ត្រ និងកម្មវិធីអនុវិស័យរដ្ឋបាលដីធ្លី

## ៥. អភិក្រមសវនកម្ម

អភិក្រមសវនកម្មផ្តោតលើដំណើរការមានហានិភ័យ ត្រូវបានប្រើប្រាស់នៅក្នុងការងារសវនកម្មនេះ។ អភិក្រមសវនកម្មនេះរាប់បញ្ចូល:

- កំណត់ត្រានូវប្រព័ន្ធគ្រប់គ្រង (កុងត្រូល) ផ្ទៃក្នុងតាមរយៈការត្រួតពិនិត្យឯកសារពាក់ព័ន្ធ និងសម្ភាសន៍មន្ត្រី
- ការកំណត់នូវកុងត្រូលគន្លឹះ និងធ្វើការប្រៀបធៀបជាមួយកុងត្រូលដែលបានរំពឹងទុក
- តេស្តសវនកម្មនូវប្រសិទ្ធភាពប្រតិបត្តិការនៃកុងត្រូល

តាមរយៈការងារសវនកម្ម ប្រតិភូសវនកម្មបានសហការកំណត់ការរំពឹងទុករួមជាមួយថ្នាក់គ្រប់គ្រង និងសវនដ្ឋានតាមដែលអាចធ្វើទៅបាន។

## ៦. សង្ខេបលទ្ធផលគន្លឹះ

ប្រតិភូសវនកម្មបានកត់សម្គាល់ឃើញនូវចំណុចខ្វះចន្លោះដូចខាងក្រោមៈ

### ១. ការទូទាត់ប្រាក់បេសកកម្ម

-ការទូទាត់ប្រាក់បេសកកម្មពុំបានភ្ជាប់របាយការណ៍លទ្ធផលសកម្មភាពការងារ។

### ២. ការអនុវត្តការងារសំណង់

-ក្នុងឆ្នាំ២០២៣ មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តបន្ទាយមានជ័យ បានចេញលិខិតអនុញ្ញាតសាងសង់បានចំនួន **៧៧**គម្រោង លិខិតបើកការដ្ឋានបានចំនួន ០៨ គម្រោង លិខិតបិទការដ្ឋានបានចំនួន ០គម្រោង មិនសមាមាត្រនឹងចំនួនចេញលិខិតអនុញ្ញាតសាងសង់។

-នៅតាមបណ្តាការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាល ក្រុង ស្រុក មិនបានបញ្ជូនឯកសារលិខិតអនុញ្ញាតសាងសង់សំណង់មកការិយាល័យសំណង់របស់មន្ទីរ។

### ៣. ការអនុវត្តការងារសុរិយោដី និងភូមិសាស្ត្រ

-ការបញ្ជូនសៀវភៅគោលបញ្ជីដីធ្លី និងតារាងសម្រង់ទៅការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាល ក្រុង ស្រុក របស់មន្ទីរពុំទាន់ពេលវេលា។

-បន្ទប់រៀបចំឯកសារចុះបញ្ជីដីធ្លីមានការជ្រាបទឹក និងខូចប្រព័ន្ធអគ្គិសនី។

### ៤. ការប្រើប្រាស់ប្រព័ន្ធព័ត៌មានភូមិសាស្ត្រ

-មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តបន្ទាយមានជ័យ ពុំមានបំពាក់ប្រព័ន្ធការពារអគ្គីភ័យនៅក្នុងបន្ទប់ម៉ាស៊ីនមេ (server)។

### ៥. ការងារសុរិយោដី និងភូមិសាស្ត្រ និងកម្មវិធីអនុវិស័យរដ្ឋបាលដីធ្លី

-ពីឆ្នាំ២០១៨ ដល់បច្ចុប្បន្នមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តបន្ទាយមានជ័យ មានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលវត្ថុខូចចំនួន **១៣,៧៥២**បណ្ណ។

## ៧. សេចក្តីសន្និដ្ឋាន

ក្នុងកំឡុងពេលធ្វើសវនកម្ម ប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងមួយចំនួនត្រូវបានកត់សម្គាល់ឃើញថា មានការរៀបចំបានល្អ និងប្រតិបត្តិប្រកបដោយប្រសិទ្ធភាព។ ប្រតិភូសវនកម្មផ្ទៃក្នុងពិនិត្យឃើញថា ថ្នាក់ដឹកនាំ និងមន្ត្រីរាជការនៅមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តបន្ទាយមានជ័យបានខិតខំប្រឹងប្រែង សហការអនុវត្តការងារតាមតួនាទីភារកិច្ចដោយអនុលោមតាមច្បាប់ និងបទប្បញ្ញត្តិដែលបានកំណត់។ ទោះជាយ៉ាងណាក៏ដោយ ក៏នៅទីសវនកម្មមួយចំនួនត្រូវបានសម្គាល់ថា ការតាក់តែងប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងត្រូវការការកែលម្អបន្ថែម និងប្រសិទ្ធភាពប្រតិបត្តិការនៃការត្រួតពិនិត្យខ្លះនៅមិនទាន់បានល្អគ្រប់ជ្រុងជ្រោយនៅឡើយ។

### ៨. វិធានការកែលម្អ

អនុសាសន៍ដែលបានផ្តល់ ក្នុងគោលបំណងធ្វើឱ្យប្រសើរឡើងនូវការអនុវត្តដំណើរការធុរកិច្ច និងការគ្រប់គ្រងផ្ទៃក្នុងរបស់សវនដ្ឋាន ត្រូវបានដាក់បញ្ចូលទៅក្នុងលទ្ធផលលម្អិត (ផ្នែក ខ)។ អនុសាសន៍ និងរបកគំហើញមួយចំនួនត្រូវបានឯកភាពជាមួយថ្នាក់ដឹកនាំជាលាយលក្ខអក្សរ។ លទ្ធផលលម្អិត (ផ្នែក ខ) ក៏មានរំលេចនូវការឆ្លើយតបរបស់ថ្នាក់គ្រប់គ្រងចំពោះអនុសាសន៍សវនកម្ម និងការរកឃើញផងដែរ។

វិធានការកែលម្អរបស់ថ្នាក់ដឹកនាំគឺមានរំលេចក្នុងផែនការសកម្មភាពជាឧបសម្ព័ន្ធទី២ ដែលបានភ្ជាប់ជាមួយ។ ផែនការសកម្មភាពកែលម្អមានបញ្ចូលលម្អិតនូវសកម្មភាពដែលសវនដ្ឋានបានឯកភាពទទួលយកដើម្បីអនុវត្តតាមអនុសាសន៍ទាំងនោះ។ អនុសាសន៍នីមួយៗ ត្រូវបានរៀបចំតាមចំណាត់ថ្នាក់ដើម្បីបង្ហាញនូវកម្រិតហានិភ័យដល់ថ្នាក់ដឹកនាំប្រសិនបើអនុសាសន៍នោះមិនត្រូវបានយកទៅអនុវត្ត។

នាពេលអនាគត នាយកដ្ឋានសវនកម្មផ្ទៃក្នុងនឹងពិនិត្យឡើងវិញលើវឌ្ឍនភាព នៃការអនុវត្តតាមអនុសាសន៍ដែលបានផ្តល់ជូនដែលជាផ្នែកមួយនៃនីតិវិធីតាមដានអនុសាសន៍សវនកម្មគ្រាមុន។

### ៩. អំណរគុណ

ក្រុមការងារសវនកម្មត្រូវបានដឹកនាំ និងត្រួតពិនិត្យដោយលោក **យូន សុជាតិ** ជាប្រធាននាយកដ្ឋានសវនកម្មផ្ទៃក្នុង និងជាប្រធានប្រតិភូ។ ប្រតិភូសវនកម្មផ្ទៃក្នុងសូមថ្លែងអំណរគុណដល់មន្ត្រីពាក់ព័ន្ធដែលបានរួមចំណែកក្នុងការងារសវនកម្មនេះ ជាពិសេសសូមថ្លែងអំណរគុណដល់លោក **មាស ដារ៉ា** ប្រធានមន្ទីរស្តីទីនៃមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តបន្ទាយមានជ័យ និងថ្នាក់ដឹកនាំដទៃទៀតចំពោះកិច្ចសហការពិគ្រោះ និងផ្តល់ព័ត៌មានព្រមទាំងមតិយោបល់ដ៏មានតម្លៃ។

## ផ្នែក ខ: លទ្ធផលសវនកម្មលម្អិត

### ១. ធនធានសវនកម្ម និងគោលសំខាន់ៗ

#### ១.១. សមាជិកប្រតិភូសវនកម្ម

នៅក្នុងការងារសវនកម្មនេះ ប្រតិភូសវនកម្មមានសមាសភាពដូចខាងក្រោម:

| | | |
|---|---|---|
| ១-លោក | **យូន សុជាតិ** | ប្រធានប្រតិភូ |
| ២-លោក | **អ៊ិត សុជា** | អនុប្រធានប្រតិភូ |
| ៣-លោក | **ហេង វាសនា** | សមាជិក |
| ៤-លោក | **ជា សីង្ហាវុធ** | សមាជិក |
| ៥-លោក | **ឌី ម៉ាល័យ** | សមាជិក |

### ១.២ ខណៈគោលសំខាន់ៗ

ខាងក្រោមគឺជាខណៈគោលសំខាន់ៗ នៅក្នុងដំណើរការសវនកម្ម:

| | |
|---|---|
| -ការធ្វើសវនកម្មបានបញ្ចប់ | ថ្ងៃទី២៥ ខែមេសា ឆ្នាំ២០២៤ |
| -សេចក្តីព្រាងលើកទី១ បានបញ្ចប់ | ថ្ងៃទី២៥ ខែមេសា ឆ្នាំ២០២៤ |
| -ការឆ្លើយតបចុងក្រោយពីថ្នាក់ដឹកនាំបានទទួល | ថ្ងៃទី២៦ ខែមេសា ឆ្នាំ២០២៤ |
| -របាយការណ៍ស្ថាពរ | ថ្ងៃទី១០ ខែឧសភា ឆ្នាំ២០២៤ |

## ២.ទិដ្ឋភាពរួមសវនកម្មផ្ទៃក្នុង

គោលបំណងរួមនៃសវនកម្មផ្ទៃក្នុងគឺជួយថ្នាក់ដឹកនាំធ្វើឱ្យកាន់តែល្អប្រសើរឡើងក្នុងដំណើរការគ្រប់គ្រងហានិភ័យ ការត្រួតពិនិត្យផ្ទៃក្នុង និងអភិបាលកិច្ច។ ការត្រួតពិនិត្យផ្ទៃក្នុងត្រូវបានអនុវត្តដោយថ្នាក់ដឹកនាំ និងមន្ត្រីដទៃទៀតដើម្បីធានាឱ្យសម្រេចបាននូវគោលបំណងដូចខាងក្រោម:

- របាយការណ៍ហិរញ្ញវត្ថុគួរឱ្យទុកចិត្តបាន
- ប្រតិបត្តិការប្រកបដោយប្រសិទ្ធភាព និងប្រសិទ្ធផល និង
- ការអនុវត្តតាមច្បាប់ និងបទដ្ឋាននានា។

របាយការណ៍នេះរួមមានការពិនិត្យលើការតាក់តែង និងប្រតិបត្តិការនៃប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងដោយសវនករនៅទីសវនកម្មអាទិភាពមួយចំនួនដែលបានឯកភាពជាមួយថ្នាក់គ្រប់គ្រងសវនដ្ឋាន។

## ៣ .ការពិនិត្យប្រព័ន្ធគ្រប់គ្រងផ្ទៃក្នុង

សវនករបានវាយតម្លៃប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង ដោយធ្វើការពិនិត្យលើសមត្ថភាពនៃដំណើរការគ្រប់គ្រងនីមួយៗ ដើម្បីសម្រេចឱ្យបានគោលបំណងគ្រប់គ្រងចំនួនប្រាំពីរមាន: ការផ្តល់សិទ្ធិ ភាពពេញលេញ ភាពត្រឹមត្រូវ សុពលភាព សុវត្ថិភាពរូបវន្ត ការដោះស្រាយកំហុស និងការបែងចែកតួនាទី។

## ៤.ព័ត៌មានអំពីសវនដ្ឋាន

មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តបន្ទាយមានជ័យមានភារកិច្ចអនុវត្តគោលនយោបាយ និងទិសដៅការងាររៀបចំដែនដី នគរូបនីយកម្ម សំណង់ សុរិយោដី និងភូមិសាស្ត្រ។ មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តបន្ទាយមានជ័យមាន÷

- ការិយាល័យរដ្ឋបាល ការិយាល័យសុរិយោដី និងភូមិសាស្ត្រ ការិយាល័យលំនៅឋាន និងការិយាល័យរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

- ការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាល ក្រុងសិរីសោភ័ណ ស្រុកអូរជ្រៅ ក្រុងប៉ោយប៉ែត ស្រុកមង្គលបូរី ស្រុកព្រះនេត្រព្រះ ស្រុកភ្នំស្រុក ស្រុកស្វាយចេក ស្រុកថ្មពួក និងស្រុកម៉ាឡៃ (ចំណុះរដ្ឋបាលសាលាក្រុង/ស្រុក)។
- មន្ត្រីសរុបចំនួន ៤៣ នាក់ ស្រី ០៦ នាក់ ក្នុងនោះមានមន្ត្រីក្រៅក្របខណ្ឌដើមចំនួន ០១ នាក់ និងមន្ត្រីកិច្ចសន្យា ១៥ នាក់ ស្រី ០៤ នាក់។

# ៥. លទ្ធផលសវនកម្ម

## ៥.១.ផ្នែកពតិមានហិរញ្ញវត្ថុ

### ក.ការទូទាត់ប្រាក់បេសកកម្ម

គោលបំណងនៃការត្រួតពិនិត្យនេះ គឺធ្វើឱ្យមានភាពត្រឹមត្រូវក្នុងការទូទាត់ប្រាក់បេសកកម្មទូទៅនៅក្នុងមន្ទីរ។ ក្រោយធ្វើសវនកម្ម មន្ត្រីសវនករពិនិត្យឃើញថា÷

ការទូទាត់ប្រាក់បេសកកម្មពុំបានភ្ជាប់របាយការណ៍លទ្ធផលសកម្មភាពការងារ។

**ករណីខាងលើនេះ** បានអនុវត្តមិនទាន់គ្រប់ជ្រុងជ្រោយតាមនីតិវិធីនៃការទូទាត់ត្រង់។

**បាតុភាពនេះ** កើតឡើងដោយសារមន្ទីរបានភ្ជាប់ឯកសារមិនទាន់បានគ្រប់ចំនួន។

**កត្តានេះ** នាំឲ្យប៉ះពាល់ដល់ប្រសិទ្ធិភាពការងារចុះបេសកកម្ម។

**មន្ទីរ** ត្រូវធ្វើរបាយការណ៍លទ្ធផលសកម្មភាពការងារឱ្យបានគ្រប់ចំនួន។

**មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តបន្ទាយមានជ័យ** ទទួលយកអនុសាសន៍របស់ប្រតិភូ នឹងធ្វើរបាយការណ៍លទ្ធផលសកម្មភាពការងារឱ្យបានគ្រប់ចំនួន។

**ប្រតិភូសវនករ** បានទទួលការឆ្លើយតបពីថ្នាក់ដឹកនាំមន្ទីរ និងបន្តតាមដាននាពេលខាងមុខទៀត។

## ៥.២.ផ្នែកអនុលោមភាព

### ក.ការអនុវត្តការងារសំណង់

គោលបំណងនៃការត្រួតពិនិត្យនេះ គឺធ្វើឱ្យមានភាពត្រឹមត្រូវក្នុងការអនុវត្តការងារសំណង់ទូទៅរបស់មន្ទីរ។ ជាក់ស្តែង មន្ត្រីសវនកររកឃើញថា÷

-ក្នុងឆ្នាំ២០២៣ មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តបន្ទាយមានជ័យ បានចេញលិខិតអនុញ្ញាតសាងសង់បានចំនួន **៧៧**គម្រោង លិខិតបើកការដ្ឋានបានចំនួន ០៨គម្រោង លិខិតបិទការដ្ឋានបានចំនួន ០គម្រោង មិនសមាមាត្រនឹងចំនួនចេញលិខិតអនុញ្ញាតសាងសង់។

-នៅតាមបណ្តាការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាល ក្រុង ស្រុក មិនបានបញ្ជូនឯកសារលិខិតអនុញ្ញាតសាងសង់សំណង់មកការិយាល័យសំណង់របស់មន្ទីរ។

**ករណីខាងលើនេះ** មិនអនុលោមតាមប្រកាសលេខ ៦៤៨ សហវ.ប្រក ចុះថ្ងៃទី០៧ ខែកក្កដា ឆ្នាំ២០០៧ ស្តីពីការផ្តល់សេវាសាធារណៈរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

**បាតុភាពនេះ** កើតឡើងដោយសារប្រជាពលរដ្ឋដែលម្ចាស់សំណង់មិនមកស្នើសុំលិខិតអនុញ្ញាតបើកបិទការដ្ឋាន។

**កត្តានេះ** នាំឱ្យប៉ះពាល់ដល់ការប្រមូលចំណូលសេវាសាធារណៈពីវិស័យសំណង់។

**មន្ទីរ** ត្រូវធ្វើការផ្សព្វផ្សាយណែនាំដល់ម្ចាស់សំណង់ត្រូវធ្វើការស្នើសុំលិខិតអនុញ្ញាតសាងសង់សំណង់ លិខិតអនុញ្ញាតបើកការដ្ឋានមុននឹងធ្វើការសាងសង់សំណង់ និងលិខិតអនុញ្ញាតបិទការដ្ឋានក្រោយពេលបញ្ចប់ការសាងសង់សំណង់។ ដោយឡែក មន្ទីរត្រូវធ្វើការណែនាំដល់ការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាល ក្រុង ស្រុក ទាំងអស់ត្រូវប្រគល់ឯកសារលិខិតអនុញ្ញាតសាងសង់សំណង់នៅពេលដែលម្ចាស់សំណង់បានសុំការអនុញ្ញាតរួចរាល់មកការិយាល័យសំណង់របស់មន្ទីរ។

**មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តបន្ទាយមានជ័យ** នឹងធ្វើការផ្សព្វផ្សាយណែនាំដល់ម្ចាស់សំណង់ត្រូវធ្វើការស្នើសុំលិខិតអនុញ្ញាតសាងសង់សំណង់ លិខិតបើកការដ្ឋានមុននឹងធ្វើការសាងសង់សំណង់ និងលិខិតបិទការដ្ឋានក្រោយពេលបញ្ចប់ការសាងសង់សំណង់។ ហើយមន្ទីរនឹងណែនាំទៅបណ្តាការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាល ក្រុង ស្រុក ត្រូវប្រគល់ឯកសារលិខិតអនុញ្ញាតសាងសង់សំណង់នៅពេលដែលម្ចាស់សំណង់បានសុំការអនុញ្ញាតរួចរាល់មកការិយាល័យសំណង់របស់មន្ទីរ។

**ប្រតិភូសវនករ** បានទទួលការឆ្លើយតបពីថ្នាក់ដឹកនាំមន្ទីរ និងបន្តតាមដាននាពេលខាងមុខទៀត។

### ខ.ការអនុវត្តការងារសុរិយោដី និងភូមិសាស្ត្រ

គោលបំណងនៃការត្រួតពិនិត្យនេះគឺធ្វើឱ្យមានភាពត្រឹមត្រូវក្នុងការអនុវត្តការងារសុរិយោដី និងភូមិសាស្ត្រទូទៅនៅក្នុងមន្ទីរ។ ក្រោយធ្វើសវនកម្ម មន្ត្រីសវនករពិនិត្យឃើញថា÷

-ការបញ្ជូនសៀវភៅគោលបញ្ជីដីធ្លី និងតារាងសម្រង់ទៅការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាល ក្រុង ស្រុក របស់មន្ទីរពុំទាន់ពេលវេលា។

-បន្ទប់រៀបចំឯកសារចុះបញ្ជីដីធ្លីមានការជ្រាបទឹក និងខូចប្រព័ន្ធអគ្គិសនី។

**ករណីខាងលើនេះ** មិនអនុលោមតាមអនុក្រឹតលេខ៦២ អនក្រ.បក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និង ប្រកាសលេខ ៧៦ ប្រក/ដនស ចុះថ្ងៃទី០១ ខែកញ្ញា ឆ្នាំ១៩៩៩ របស់ក្រសួងរៀបចំដែនដី នគរូប នីយកម្ម និងសំណង់ ស្តីពីតួនាទី ភារកិច្ច និងរចនាសម្ព័ន្ធរបស់មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្ត-ក្រុង និងតួនាទីភារកិច្ច របស់បណ្តាការិយាល័យក្រោមឱវាទ។

**បញ្ហានេះ** កើតឡើងដោយសារមន្ទីរមិនទាន់បាន បញ្ជូនសៀវភៅគោលបញ្ជីដីធ្លី និងតារាងសម្រង់ទៅការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាល ក្រុង ស្រុក ឱ្យបានទាន់ពេលវេលា និងជួសជុលបន្ទប់រៀបចំឯកសារចុះបញ្ជីដីធ្លីដែលមានការជ្រាបទឹក និងខូចប្រព័ន្ធអគ្គិសនី។

**កត្តានេះ** នាំឱ្យប៉ះពាល់ដល់ប្រសិទ្ធភាពការងារ និងពុំស្របតាមអនុក្រឹត្យ និងប្រកាសខាងលើ។

**មន្ទីរ** ត្រូវបញ្ជូនសៀវភៅគោលបញ្ជីដីធ្លី និងតារាងសម្រង់ទៅការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាល ក្រុង ស្រុក ឱ្យបានទាន់ពេលវេលា និងត្រូវជួសជុលបន្ទប់រៀបចំឯកសារចុះបញ្ជីដីធ្លីដែលជ្រាបទឹក និងខូចប្រព័ន្ធអគ្គិសនីជាបន្ទាន់។

**មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តបន្ទាយមានជ័យ** នឹងបញ្ជូនសៀវភៅគោលបញ្ជីដីធ្លី និងតារាងសម្រង់ទៅការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាល ក្រុង ស្រុក ឱ្យបានទាន់ពេលវេលា និងជួសជុលបន្ទប់រៀបចំឯកសារចុះបញ្ជីដីធ្លីដែលជ្រាបទឹក និងប្រព័ន្ធអគ្គិសនីក្នុងពេលឆាប់ៗនេះ។

**ប្រតិភូសវនករ** បានទទួលការឆ្លើយតបពីថ្នាក់ដឹកនាំមន្ទីរ និងបន្តតាមដាននាពេលខាងមុខទៀត។

### គ.ការប្រើប្រាស់ប្រព័ន្ធព័ត៌មានភូមិសាស្ត្រ

គោលបំណងនៃការត្រួតពិនិត្យនេះគឺធ្វើឱ្យមានភាពត្រឹមត្រូវមានសុវត្ថិភាពក្នុងការប្រើប្រាស់ប្រព័ន្ធព័ត៌មានភូមិសាស្ត្រ។ ក្រោយធ្វើសវនកម្ម មន្ត្រីសវនករពិនិត្យឃើញថា÷

មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តបន្ទាយមានជ័យ ពុំមានបំពាក់ប្រព័ន្ធការពារអគ្គិភ័យនៅក្នុងបន្ទប់ម៉ាស៊ីនមេ (server)។

**ករណីខាងលើនេះ** មិនអនុលោមតាមប្រកាសលេខ១៤៣៦ សហវ.ប្រក ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០១៦ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីការដាក់ឱ្យប្រើប្រាស់ឯកសារស្តីពីការគ្រប់គ្រងប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងបច្ចេកវិទ្យាព័ត៌មាន។

**បាតុភាពនេះ** កើតឡើងដោយសារមន្ទីរ ពុំបានបំពាក់ប្រព័ន្ធការពារអគ្គិភ័យនៅក្នុងបន្ទប់ដាក់ម៉ាស៊ីនមេ (server)។

**កត្តានេះ** នាំឱ្យប៉ះពាល់ដល់ប្រព័ន្ធសុវត្ថិភាពក្នុងការគ្រប់គ្រងប្រព័ន្ធព័ត៌មានភូមិសាស្ត្រ (GIS)។

**មន្ទីរ**រៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តបន្ទាយមានជ័យ ត្រូវបំពាក់ប្រព័ន្ធការពារអគ្គិភ័យបន្ទប់ម៉ាស៊ីនមេ (server) ជាបន្ទាន់។

**មន្ទីរ** ទទួលយកអនុសាសន៍របស់ប្រតិភូសវនករ នឹងបំពាក់ប្រព័ន្ធការពារអគ្គិភ័យនៅក្នុងបន្ទប់ម៉ាស៊ីនមេ (server) ក្នុងពេលឆាប់ៗនេះ។

**ប្រតិភូសវនករ** បានទទួលការឆ្លើយតបពីថ្នាក់ដឹកនាំមន្ទីរ និងបន្តតាមដាននាពេលខាងមុខទៀត។

### ឃ.ការងារសុរិយោដី និងភូមិសាស្ត្រ និងកម្មវិធីអនុវិស័យរដ្ឋបាលដីធ្លី

គោលបំណងនៃការត្រួតពិនិត្យនេះគឺធ្វើឱ្យមានភាពត្រឹមត្រូវមានសុវត្ថិភាពក្នុងការងារសុរិយោដី និងភូមិសាស្ត្រ និងកម្មវិធីអនុវិស័យរដ្ឋបាលដីធ្លីទូទៅនៅក្នុងមន្ទីរ។ ក្រោយធ្វើសវនកម្ម មន្ត្រីសវនករពិនិត្យឃើញថា÷

ពីឆ្នាំ២០១៨ ដល់បច្ចុប្បន្នមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តបន្ទាយមានជ័យ មានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលវត្ថុខូចចំនួន **១៣,៧៥២**បណ្ណ។

**ករណីខាងលើនេះ** មិនអនុលោមទៅតាមសារាចរណែនាំលេខ ០០៣ ដនស.សជ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០០០ ស្តីពីការអនុវត្តនីតិវិធីនៃការកសាងប្លង់សុរិយោដី និងសៀវភៅគោលបញ្ជីដីធ្លី (ការចុះបញ្ជីដីមានលក្ខណៈជាប្រព័ន្ធ)។

**បាតុភាពនេះ** កើតឡើងដោយសារ÷

- បញ្ហាទឹកថ្នាំ និងត្រាម
- បញ្ហា QR Code មិនដំណើរការ
- មន្ត្រីទទួលបន្ទុកក្នុងការព្រីនសន្លឹកបណ្ណមានការធ្វេសប្រហែស (ព្រីនម្តងខុសលេខក្បាលដីខាងមុខ ព្រីនម្តងខុសលេខក្បាលដីខាងក្រោយ)។

**កត្តានេះ** នាំឱ្យប៉ះពាល់ដល់ប្រសិទ្ធភាពនៃការអនុវត្តនីតិវិធីនៃការកសាងប្លង់សុរិយោដី និងសៀវភៅគោលបញ្ជីដីធ្លី។

**មន្ទីរ** ត្រូវបង្កើតគណកម្មការដើម្បីត្រួតពិនិត្យសន្លឹកបណ្ណខូច និងបូកសរុបដើម្បីដុតកម្ទេច យោងលើលិខិតលេខ ៣២៩ អ/សជភ ចុះថ្ងៃទី១៣ ខែសីហា ឆ្នាំ២០១៩ ស្តីពីការគ្រប់គ្រងសន្លឹកវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ។

**មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តបន្ទាយមានជ័យ** នឹងបង្កើតគណកម្មការត្រួតពិនិត្យសន្លឹកបណ្ណខូច និងបូកសរុបដើម្បីដុតកម្ទេច។

**ប្រតិភូសវនករ** បានទទួលការឆ្លើយតបពីថ្នាក់ដឹកនាំមន្ទីរ និងបន្តតាមដាននាពេលខាងមុខទៀត។

## ៦. សេចក្តីសន្និដ្ឋានរួម

ផ្អែកតាមលទ្ធផលធ្វើសវនកម្មជាក់ស្តែងនៅមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តបន្ទាយមានជ័យ សម្រាប់ការិយបរិច្ឆេទ២០២៣ លើប្រព័ន្ធគ្រប់គ្រង និងយន្តការនៃដំណើរការក្នុង

វិសាលភាព និងគោលបំណងខាងលើ ប្រតិភូសវនកម្មផ្ទៃក្នុងអាចធ្វើសេចក្ដីសន្និដ្ឋានលើចំណុចខ្វះចន្លោះ ដែលត្រូវពង្រឹងបន្ថែមមានដូចជា ការទូទាត់ប្រាក់បេសកកម្ម ការអនុវត្តការងារសំណង់ ការអនុវត្តការងារសុរិយោដី និងភូមិសាស្ត្រ ការប្រើប្រាស់ប្រព័ន្ធព័ត៌មានភូមិសាស្ត្រ និងការងារសុរិយោដី និងភូមិសាស្ត្រ និងកម្មវិធីអនុវិស័យរដ្ឋបាលដីធ្លី ដើម្បីជំរុញប្រសិទ្ធភាពការងារឱ្យបានប្រសើរឡើងនាឆ្នាំបន្ទាប់។

## ៧ .ផែនការសកម្មភាពកែលម្អ

ដើម្បីធានាប្រសិទ្ធភាពអនុវត្តការកែលម្អអនុសាសន៍ដែលប្រតិភូសវនករបានផ្តល់ជូន ថ្នាក់ដឹកនាំនៃមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តបន្ទាយមានជ័យបានឯកភាពលើផែនការសកម្មភាពដូចបានកំណត់ក្នុងតារាងនៃឧបសម្ព័ន្ធទី២។

ថ្ងៃសុក្រ ៣កើត ខែពិសាខ ឆ្នាំរោង ឆស័ក ព.ស.២៥៦៧

រាជធានីភ្នំពេញ ថ្ងៃទី ១០ ខែឧសភា ឆ្នាំ២០២៤

**ប្រធាននាយកដ្ឋាន៦**

យួន_សុជាតិ

## ២. ឧបសម្ព័ន្ធទី ២ - ផែនការសកម្មភាពកែលម្អ

របាយការណ៍ : សវនកម្មនៅមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តបន្ទាយមានជ័យ ការិយបរិច្ឆេទ២០២៣

របាយការណ៍លេខ: ......០៤៩...... /របក ចុះថ្ងៃទី.....១០.....ខែ.ឧសភា ឆ្នាំ២០២៤

- ខ្ពស់: ដើម្បីកាត់បន្ថយហានិភ័យសំខាន់ៗដែលនាំឱ្យខូចខាត ងាយរងគ្រោះ ឬបាត់បង់កេរ្តិ៍ឈ្មោះរបស់ស្ថាប័ន។
- មធ្យម: ដើម្បីចាត់វិធានការលើបញ្ហាដែលមិនទាន់មានលក្ខណៈល្អប្រសើរ និងដែលសំខាន់ ពង្រឹងប្រព័ន្ធ និងនីតិវិធី
- ទាប: ពង្រឹងការត្រួតពិនិត្យដែលមានស្រាប់ឬចងក្រងឯកសារក្នុងទីដែល មិនសូវសំខាន់
- អ.ព: អនុវត្តតាមអនុសាសន៍ឱ្យបានពេញលេញ និងកាត់បន្ថយនូវហានិភ័យឱ្យដល់កម្រិតមួយអាចទទួលយកបាន ។

| អនុសាសន៍លេខ | សកម្មភាពដែលថ្នាក់ដឹកនាំបានឯកភាព | អាទិភាព* | មន្ត្រីទទួលបន្ទុក | កាលបរិច្ឆេទឯកភាពបញ្ចប់ការអនុវត្ត |
|---|---|---|---|---|
| **១.ផ្នែកប្រតិបត្តិការ** | | | | |
| ក.មន្ទីរត្រូវធ្វើរបាយការណ៍លទ្ធផលសកម្មភាពការងារឱ្យបានគ្រប់ចំនួនពីមុខសញ្ញាទទួល។ | អ.ព | មធ្យម | ប្រធានមន្ទីរ | មន្ទីរទទួលយកអនុសាសន៍របស់ប្រតិភូ នឹងធ្វើរបាយការណ៍លទ្ធផលសកម្មភាពការងារឱ្យបានគ្រប់ចំនួន។ |
| **២.ផ្នែកអនុលោមភាព** | | | | |
| ក -មន្ទីរ ត្រូវធ្វើការផ្សព្វផ្សាយណែនាំដល់ម្ចាស់សំណង់ត្រូវធ្វើការស្នើសុំលិខិតអនុញ្ញាតសាងសង់សំណង់ លិខិតអនុញ្ញាតបើកការដ្ឋានមុននឹងធ្វើការសាងសង់សំណង់ និងលិខិតអនុញ្ញាតបិទការដ្ឋានក្រោយពេលបញ្ចប់ការសាងសង់សំណង់។<br>-មន្ទីរ ត្រូវធ្វើការណែនាំដល់ការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាល ក្រុង ស្រុក ទាំងអស់ត្រូវប្រគល់ឯកសារលិខិតអនុញ្ញាតសាងសង់សំណង់នៅពេលដែលម្ចាស់សំណង់បាន | អ.ព | មធ្យម | ប្រធានមន្ទីរ | -មន្ទីរ នឹងធ្វើការផ្សព្វផ្សាយណែនាំដល់ម្ចាស់សំណង់ត្រូវធ្វើការស្នើសុំលិខិតអនុញ្ញាតសាងសង់សំណង់ លិខិតបើកការដ្ឋានមុននឹងធ្វើការសាងសង់សំណង់ និងលិខិតបិទការដ្ឋានក្រោយពេលបញ្ចប់ការសាងសង់សំណង់។<br>-មន្ទីរ នឹងណែនាំទៅបណ្ដាការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាល ក្រុង ស្រុក ត្រូវប្រគល់ឯកសារលិខិតអនុញ្ញាតសាងសង់សំណង់នៅពេលដែលម្ចាស់សំណង់ |

| | | | | |
|---|---|---|---|---|
| សុំការអនុញ្ញាតឱ្យចូលរាល់មកការិយាល័យសំណង់របស់មន្ទីរ។ | | | | បានសុំការអនុញ្ញាតឱ្យចូលរាល់មកការិយាល័យសំណង់របស់មន្ទីរ។ |
| **ខ.** មន្ទីរ ត្រូវបញ្ជូនសៀវភៅគោលបញ្ជីដីធ្លី និងតារាងសម្រង់ទៅការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលក្រុង ស្រុក ឱ្យបានទាន់ពេលវេលា និងត្រូវជួសជុលបន្ទប់រៀបចំឯកសារចុះបញ្ជីដីធ្លីដែលជ្រាបទឹក និងខូចប្រព័ន្ធអគ្គិសនីជាបន្ទាន់។ | អ.ព | មធ្យម | ប្រធានមន្ទីរ | មន្ទីរ នឹងបញ្ជូនសៀវភៅគោលបញ្ជីដីធ្លី និងតារាងសម្រង់ទៅការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលក្រុង ស្រុក ឱ្យបានទាន់ពេលវេលា និងជួសជុលបន្ទប់រៀបចំឯកសារចុះបញ្ជីដីធ្លីដែលជ្រាបទឹក និងប្រព័ន្ធអគ្គិសនីក្នុងពេលឆាប់ៗនេះ។ |
| **គ.** មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តបន្ទាយមានជ័យ ត្រូវបំពាក់ប្រព័ន្ធការពារអគ្គិភ័យបន្ទប់ម៉ាស៊ីនមេ (server) ជាបន្ទាន់។ | អ.ព | មធ្យម | ប្រធានមន្ទីរ | មន្ទីរ ទទួលយកអនុសាសន៍របស់ប្រតិភូសវនករ នឹងបំពាក់ប្រព័ន្ធការពារអគ្គិភ័យនៅក្នុងបន្ទប់ម៉ាស៊ីនមេ (server) ក្នុងពេលឆាប់ៗនេះ។ |
| **ឃ.** មន្ទីរត្រូវបង្កើតគណៈកម្មការដើម្បីត្រួតពិនិត្យសន្លឹកបណ្ណខូច និងប្លុកសរុបដើម្បីដុតកម្ទេច យោងលើលិខិតលេខ ៣២៩ អ/សជភ ចុះថ្ងៃទី១៣ ខែសីហា ឆ្នាំ២០១៩ ស្ដីពីការគ្រប់គ្រងសន្លឹកវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលវត្ថុ។ | អ.ព | មធ្យម | ប្រធានមន្ទីរ | មន្ទីរនឹងបង្កើតគណៈកម្មការត្រួតពិនិត្យសន្លឹកបណ្ណខូច និងប្លុកសរុបដើម្បីដុតកម្ទេច។ |

**ប្រធានមន្ទីរ**

មាស ដារ៉ា

**ប្រតិភូសវនករ**

យួន_សុជាតិ

## ៣.ឧបសម្ព័ន្ធទី៣ - តារាងចំណាយថវិការដ្ឋ និងតារាងប្រើប្រាស់ប្រេងឥន្ធនៈ

### ៣.១.តារាងចំណាយថវិការដ្ឋ របស់មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តបន្ទាយមានជ័យ

| ល.រ | បរិយាយ | ច្បាប់ហិរញ្ញវត្ថុ ឆ្នាំ២០២៣ | ឥណទានថ្មី | ទឹកប្រាក់តាមអាណត្តិ | បង់សំណែសចំណាយ | ចំណាយជាក់ស្តែង | លំអៀង | សមតុល្យ |
|---|---|---|---|---|---|---|---|---|
| ១ | ការទិញ (ជំពូក ៦០) | 117.100.000 | 117.100.000 | 96.160.640 | 0 | 96.160.640 | 0 | 20.939.360 |
| ២ | សេវាខាងក្រៅ (ជំពូក ៦១) | 109.400.000 | 109.400.000 | 73.966.483 | 0 | 73.966.483 | 0 | 35.433.517 |
| ៣ | បន្ទុកបុគ្គលិក( ជំពូក ៦៤ ) | 1.088.300.000 | 1.088.300.000 | 951.905.000 | 0 | 951.905.000 | 0 | 136.395.000 |
| **សរុប** | | **1.314.800.000** | **1.314.800.000** | **1.122.032.123** | **0** | **1.122.032.123** | **0** | **192.767.877** |

ថ្ងៃព្រហស្បតិ៍ ២រោច ខែចេត្រ ឆ្នាំរោង ឆស័ក ព.ស. ២៥៦៧
ថ្ងៃទី២៥ ខែមេសា ឆ្នាំ២០២៤
**ប្រតិភូសទនករ**

បាទឃើញ និងពិនិត្យត្រឹមត្រូវ
**ប្រធានការិយាល័យរដ្ឋបាល**

ទន ណាវី

បាទឃើញ និងឯកភាព
**ប្រធានមន្ទីរ**

មាស ដារ៉ា

យួន សុជាតិ

### ៣.២. តារាងប្រើប្រាស់ប្រេងឥន្ធនៈ របស់មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តបន្ទាយមានជ័យ

| ល.រ | ប្រភេទប្រេងឥន្ធនៈ | បញ្ចូល | | បញ្ចេញ | សមតុល្យ |
|---|---|---|---|---|---|
| | | ផ្គត់ផ្គង់ | រដ្ឋទេយ្យ | | |
| ១ | ប្រេងសាំង (លីត្រ) | 4.911 | 0 | 4.911 | 0 |
| ២ | ប្រេងម៉ាស៊ូត (លីត្រ) | 623 | 0 | 623 | 0 |

ថ្ងៃព្រហស្បតិ៍ ២រោច ខែចេត្រ ឆ្នាំរោង ឆស័ក ព.ស. ២៥៦៧
ថ្ងៃទី២៥ ខែមេសា ឆ្នាំ២០២៤
**ប្រតិភូសវនករ**

យួន_សុជាតិ

បានឃើញ និងពិនិត្យត្រឹមត្រូវ
ជ. **ប្រធានការិយាល័យរដ្ឋបាល**

ទន ណាវី

បានឃើញ និងឯកភាព
**ប្រធានមន្ទីរ**

មាស ដារ៉ា